កម្មវិធីទារប្រាក់
ឧបត្ថម្ភក្មេងនៃ
រដ្ឋវ៉ាស៊ីនតោន



# សិទ្ធិធ្វើ
# សវនាការ
# ផ្នែកឧបត្ថម្ភ
# ក្មេង




Washington State
Department of Social
& Health Services
DCS Division of Child Support

## តើមានអ្វីកើតឡើងនៅពេលធ្វើសវនាការផ្នែកឧបត្ថម្ភក្មេង?

សវនាការរដ្ឋបាលគឺមិនមែនជាផ្លូវការ និងការប្រជុំ "user-friendly" ធ្វើនៅបន្ទប់ប្រជុំ មិនមែននៅកន្លែងតុលាការទេ ។

អ្នកធ្វើការសំរេចដោយឯករាជ្យដែលហៅថាចៅក្រមផ្នែករដ្ឋបាល (ALJ) ធ្វើសវនាការរដ្ឋបាល ។ ចៅក្រម ALJ ធ្វើការឲ្យការិយាល័យសវនាការរដ្ឋបាល (OAH) ។ ការិយាល័យ OAH មិនមែនជាផ្នែកនៃក្រសួងសង្គមកិច្ចនឹងសុខាភិបាល (DSHS) ឬជានាយកដ្ឋាន ឧបត្ថម្ភក្មេង (DCS) ទេ ។

ចៅក្រម ALJ សំរេចអំពីសំណុំរឿងឧបត្ថម្ភក្មេងរបស់អ្នក ដោយប្រើករណីអង្គហេតុនានា និងច្បាប់ ។ អ្នកត្រូវអញ្ជើញទៅធ្វើសវនាការដោយផ្ទាល់ ឬធ្វើតាមទូរស័ព្ទ ។ អ្នកនិយាយរឿងចំណែករបស់អ្នក ក៏ដូចជានាយកដ្ឋាន DCS និងឪពុកម្តាយដទៃទៀតនិយាយចំណែកគេដែរ ។ សវនាការជាតួយ៉ាងនឹងប្រើរយពេលពីមួយម៉ោងទៅពីរម៉ោង ។

## តើខ្ញុំត្រូវការមេធាវីម្នាក់ឬ?

មនុស្សជាច្រើនតំណាងឲ្យខ្លួនរបស់គេនៅពេលសវនាការ ។ អ្នកាចតំណាងឲ្យខ្លួនរបស់អ្នក ឬមានមេធាវី, មិត្តសំឡាញ់, សាច់ញាតិ, ឬជនដទៃផ្សេងទៀត តាមជំរើសរបស់អ្នកសំរាប់តំណាងឲ្យអ្នក ។ ស្នើសុំមិត្តភ័ក្របឬសាច់ញាតិដើម្បីឲ្យគេផ្តល់អនុសាសន៍ពីការរកមេធាវីម្នាក់ ឬទាក់ទងកន្លែងមួយនៃកន្លែងខាងក្រោមនេះ:

- Northwest Justice Project
  888-201-1014
  www.nwjustice.org

- Northwest Women's Law Center
  206-621-7691

សាលាច្បាប់ខ្លះ, សមាគមសេវាមេធាវីស្ម័គ្រចិត្ត, និងអង្គការមិនយកកម្រៃផ្នែកច្បាប់ដទៃផ្សេង ទៀតក៏អាចផ្តល់ជំនួយបាន ។ ថែមពីលើនោះ សមាគមក្រុមអ្នកច្បាប់នៅខោនធីរបស់អ្នក ឬសេវាបញ្ជូន (ជាទូទៅមានរាយឈ្មោះនៅខាងចុងនៃជំពូកឈ្មោះ "មេធាវី" ក្នុងសៀវភៅទូរស័ព្ទ ជំពូកការផ្សាយទំនិញ) ប្រហែលអាចណែនាំអ្នករកមេធាវីនៅក្នុងសហគមន៍របស់ អ្នកបាន ។

## តើអ្នកតំណាងនៃនាយកដ្ឋាន DCS អាចធ្វើអ្វីសំរាប់ខ្ញុំ?

អ្នកតំណាងនៃនាយកដ្ឋាន DCS គឺជាមេធាវីដែលតំណាងក្នុងប្រយោជន៍ដល់នាយកដ្ឋាន DCS ។ ជននេះមិនមែនជាអ្នកតំណាងរបស់អ្នកទេ ។ នាយកដ្ឋាន DCS អាចមាន បំណង ដែលខុសពីបំណងរបស់អ្នក ។ ហេតុដូច្នេះ អ្នកតំណាងឲ្យនាយកដ្ឋាន DCS អាចពន្យល់ពីរបៀបដែលសវនាការដោះស្រាយ និងអំពីច្បាប់និងបញ្ញត្តិទូទៅសំរាប់សវនាការរបស់អ្នក ។ បើសិនជាអ្នកចង់ជៀសវាងធ្វើសវនាការ អ្នកប្រហែលអាចទទួលការយល់ព្រមឬផ្សះផ្សាសំណុំរឿងរបស់អ្នកជាមួយអ្នកតំណាងនាយកដ្ឋាន DCS ។ គ្រប់គូភាគីទាំងអស់និងនាយកដ្ឋាន DCS ត្រូវតែយល់ព្រមមុនសំណុំរឿងអាចផ្សះផ្សា ។

## តើខ្ញុំនឹងដឹងពីសវនាការរបស់ខ្ញុំ ថានឹងធ្វើនៅពេលណា?

ការិយាល័យ OAH ផ្ញើឲ្យអ្នកនូវសេចក្តីជូនដំណឹងនៃសវនាការ ដែលនឹងប្រាប់អ្នកពីថ្ងៃ, ពេលម៉ោង, នឹងទីកន្លែងធ្វើសវនាការ ។ សូមឲ្យប្រាកដ អ្នកត្រូវរក្សាផ្តល់ដំណឹងពីអាសយដ្ឋានផ្ញើសំបុត្របច្ចុប្បន្នទៅឲ្យការិយាល័យ OAH និងនាយកដ្ឋាន DCS ។ បើសិនជាអ្នកមានសវនាការតាមទូរស័ព្ទ អ្នកត្រូវតែប្រាប់លេខទូរស័ព្ទរបស់អ្នកទៅការិយាល័យ OAH និងនាយកដ្ឋាន DCS ។ ករណីនេះអនុញ្ញាតឲ្យចៅក្រម ALJ ឬនាយកដ្ឋាន DCS ទូរស័ព្ទមកអ្នកនៅថ្ងៃធ្វើសវនាការ ។

## តើខ្ញុំអាចស្នើសុំសំរាប់ប្តូរថ្ងៃ ឬពេលម៉ោងផ្សេងសំរាប់ធ្វើសវនាការរបស់ខ្ញុំរបៀបណា?

បើសិនជាអ្នកមិនអាចអញ្ជើញទៅធ្វើសវនាការរបស់អ្នកតាមថ្ងៃ និងពេលម៉ោងដែលកំណត់បានទេ អ្នកអាចស្នើសុំសំរាប់លើកពេលវេលា (ពន្យាពេល) ។ ចូរទាក់ទងទៅការិយាល័យ OAH ឬនាយកដ្ឋាន DCS យ៉ាងហោចណាស់មួយអាទិត្យមុនថ្ងៃធ្វើសវនាការ ។ គូភាគីម្ខាងទៀតប្រហែលជាមិនចង់លើកពេលវេលាទេ ។ បើសិនជាគូភាគីម្ខាងទៀតមិនយល់ព្រម ចៅក្រម ALJ សំរេចថា តើសវនាការនឹងត្រូវប្តូរពេលដែរឬទេ ។ លេខទូរស័ព្ទរបស់ ការិយាល័យ OAH និងនាយកដ្ឋាន DCS មាននៅក្នុងសេចក្តីជូនដំណឹងនៃសវនាការ ។

## តើមានអ្វីកើតឡើង បើសិនជាខ្ញុំមិនបង្ហាញខ្លួននៅថ្ងៃធ្វើសវនាការ ?

បើសិនជាអ្នកមិនអាចបង្ហាញខ្លួននៅថ្ងៃធ្វើសវនាការបាន នោះនឹងមានការប៉ះពាល់ដល់សិទ្ធិសវនាការរបស់អ្នក ។ ចៅក្រម ALJ សំរេចបញ្ហាឧបត្ថម្ភក្មេងដោយប្រើការបង្ហាញអង្គហេតុ និងភស្តុតាងនានានៅពេលធ្វើសវនាការ ។ បើសិនជាអ្នកមិនអញ្ជើញទៅ អ្នកនឹងមិនអាចជំរាបទៅចៅក្រម ALJ នូវអ្វីដែលអ្នកគិតថាមានសារៈសំខាន់ ។ អ្នកអាចទូរស័ព្ទទៅការិយាល័យ OAH ឬនាយកដ្ឋាន DCS បើសិនជាមានបញ្ហាក្នុងនាទីចុងក្រោយធ្វើឲ្យអ្នកខកខានមិនបានទៅធ្វើសវនាការ ។

## តើខ្ញុំនឹងចូលរួមធ្វើសវនាការដោយផ្ទាល់ខ្លួន ឬតាមទូរស័ព្ទ ?

សេចក្តីជូនដំណឹងនៃសវនាការនឹងប្រាប់អ្នក ថាតើទីកន្លែងណាដែលអ្នកត្រូវទៅធ្វើសវនាការ។ អ្នកត្រូវការអញ្ជើញទៅការិយាល័យនាយកដ្ឋាន DCS, ការិយាល័យ OAH ឬការិយាល័យបំរើសេវាសហគមន៍ (CSO) ។ បើសិនជាមានការណែនាំប្រាប់អ្នកឲ្យអញ្ជើញទៅទីកន្លែងពិតប្រាកដមួយដើម្បីធ្វើសវនាការ សូមដឹងថា គូភាគីផ្សេងទៀតអាចអញ្ជើញទៅក្នុងបន្ទប់ជាមួយអ្នកដែរនៅពេលធ្វើសវនាការ និងថាចៅក្រម ALJ អាចធ្វើសវនាការតាមទូរស័ព្ទពីកន្លែងដទៃទៀត ។

ជួនកាលសេចក្តីជូនដំណឹងនឹងប្រាប់អ្នកឲ្យធ្វើសវនាការតាមទូរស័ព្ទ ។ បើសិនជាអ្នកមានកង្វល់និងចង់ប្តូរទម្រង់នៃសវនាការ ចូរទាក់ទងការិយាល័យ OAH ឬនាយកដ្ឋាន DCS ឲ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន ។

## តើខ្ញុំត្រូវធ្វើដូចម្តេច បើសិនជាខ្ញុំមានកង្វល់អំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់ខ្ញុំ?

- ប្រាប់ទៅនាយកដ្ឋាន DCS ឬការិយាល័យ OAH ឲ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន បើសិនជាអ្នកមានកង្វល់ពីសុវត្ថិភាពរបស់អ្នកនៅពេលធ្វើសវនាការ ។
- ទូរស័ព្ទទៅនាយកដ្ឋាន DCS ឬការិយាល័យ OAH និងស្នើសុំធ្វើសវនាការតាមទូរស័ព្ទ បើសិនជាអ្នកមានកង្វល់ពីសុវត្ថិភាពរបស់អ្នកនៅពេលធ្វើសវនាការ ។
- និយាយប្រាប់ទៅនាយកដ្ឋាន DCS បើសិនជាមានដីកាការពារឬដីកាឃុំឃាំងសំរាប់ ប្រើរវាងអ្នកនិងគូភាគីផ្សេងទៀត។ នាយកដ្ឋាន DCS ប្រហែលមិនដឹងអំពីពត៌មាននេះទេ ។
- បើសិនជាអ្នកមានដីកាការពារ ឬមានការភ័យខ្លាចចំពោះគូភាគីដទៃទៀត អ្នកមិនចាំបាច់អញ្ជើញទៅដោយផ្ទាល់ក្នុងពេលជាមួយគ្នាទេ ។

## តើសវនាការប្រជុំតាមទូរស័ព្ទមានដំណើរការដោយរបៀបណា?

អ្នក, ចៅក្រម ALJ, នាយកដ្ឋាន DCS, សាក្សី, ឬមនុស្សដទៃម្នាក់ឬច្រើននាក់ទៀត ដែលមានទំនាក់ទំនងនៅក្នុងសវនាការអាចចូលរួមចំណែកតាមទូរស័ព្ទ ។ យ៉ាងហោចណាស់មួយថ្ងៃមុនពេលធ្វើសវនាការរបស់អ្នក ចូរឲ្យប្រាកដបើសិនជាអ្នកអាចទៅកន្លែងពិសេសណាមួយ ឬបើសិនជាអ្នកអាចរង់ចាំសំរាប់គេទូរស័ព្ទមក ។

បើសិនជានាយកដ្ឋាន DCS ឬការិយាល័យ ALJ ទូរស័ព្ទមកអ្នក, សូមឲ្យប្រាកដថានាយកដ្ឋាន DCS និងចៅក្រម ALJ មានលេខទូរស័ព្ទត្រឹមត្រូវ សំរាប់កន្លែងដែលអ្នករង់ចាំនៅពេលធ្វើសវនាការ ។ អ្នកអាចជ្រើសយកលេខទូរស័ព្ទនៅកន្លែងណាមួយដែលអ្នកចង់ ។ សូមឲ្យប្រាកដទូរស័ព្ទនោះគ្មានអ្នកណាប្រើទេ ដើម្បីកុំឲ្យមានសញ្ញាទូរស័ព្ទជាប់ ពេលដែលគេទូរស័ព្ទមកអ្នក ។

បើសិនជាអ្នកធ្វើសវនាការតាមទូរស័ព្ទ អ្នកអាចផ្ញើតាមប៉ុស្តិ៍ ឬផ្ញើទូរសារនូវក្រដាសចម្លងគ្រប់ទាំងអស់ទៅចៅក្រម ALJ និងទៅគូភាគីដទៃទៀត យ៉ាងហោចណាស់មួយអាទិត្យមុនពេល ។ អ្នកតំណាងនៃនាយកដ្ឋាន DCS ប្រហែលអាចជួយអ្នកចំពោះរឿងនេះ ។ **គូសខ្មៅកុំឲ្យឃើញអាសយដ្ឋានរបស់អ្នកនិងពត៌មានដទៃទៀតដែលអ្នកមិនចង់បញ្ចេញទៅ ឲ្យគូភាគីដទៃទៀត ។**

## តើខ្ញុំត្រូវរៀបចំរបៀបណាសំរាប់សវនាការរបស់ខ្ញុំ?

យកក្រដាសសំរាប់សរសេរកត់ត្រាសេចក្តីមកជាមួយអ្នក ដើម្បីរៀបចំពត៌មាននានា និងជួយអ្នកឲ្យនឹកឃើញនូវអ្វីដែលអ្នកចង់និយាយ ។ ចៅក្រម ALJ ផ្អែកការសំរេចរបស់គេទៅលើពត៌មាននិងសេចក្តីថ្លែងដែលអ្នកនិងសាក្សីដទៃទៀត ដោយរួមទាំងនាយកដ្ឋាន DCS ដែល បានផ្តល់ឲ្យនៅពេលធ្វើសវនាការ ។

ពិភាក្សាសំណុំរឿងរបស់អ្នកជាមួយអ្នកតំណាងនាយកដ្ឋាន DCS នៅមុនថ្ងៃធ្វើសវនាការ ។ ករណីនេះនឹងអនុញ្ញាតឲ្យអ្នកដឹងពិតប្រាកដនូវអ្វីដែលជាបញ្ហា ។ អ្នកក៏អាចប្រើពេលនោះ ដើម្បីសំរេចថា តើអ្នកត្រូវសុំយោបល់ពីមេធាវីឬទេ ។

## តើខ្ញុំអាចផ្សះផ្សាសំណុំរឿងដោយមិនចាំបាច់ធ្វើសវនាការបានឬទេ ?

ចូរទាក់ទងទៅនាយកដ្ឋាន DCS បើសិនជាអ្នកចង់សាកល្បងដោះស្រាយការព្រមព្រៀងមុនពេលធ្វើសវនាការ ។ គ្រប់គូភាគីទាំងអស់និងនាយកដ្ឋាន DCS ត្រូវតែព្រមព្រៀងមុនពេលសំណុំរឿងអាចផ្សះផ្សាបាន ។ បើសិនជាអ្នក, គូភាគីដទៃទៀត, និងអ្នកតំណាងនាយកដ្ឋាន DCS មិនអាចព្រមព្រៀងគ្នា អ្នកនៅតែមានសិទ្ធិធ្វើសវនាការ ។ ការិយាល័យ OAH នឹងផ្ញើសេចក្ដីជូនដំណឹងនៃសវនាការឲ្យអ្នក ។ បើសិនជាអ្នកចង់ទាក់ទងទៅ នាយកដ្ឋាន DCS មុនពេលដែលអ្នកទទួលសេចក្ដីជូនដំណឹងនៃសវនាការ ចូរទូរស័ព្ទលេខ **800-422-KIDS** ដើម្បីឲ្យដឹងថាតើការិយាល័យនាយកដ្ឋាន DCS ណាមួយនឹងកាន់ សំណុំរឿងរបស់អ្នក ។

## តើខ្ញុំត្រូវការនាំយករបស់អ្វីខ្លះដើម្បីទៅធ្វើសវនាការ ?

ចៅក្រម ALJ នឹងផ្អែកសេចក្ដីសំរេចលើពត៌មាននិងសេចក្ដីថ្លែងដែលអ្នក និងសាក្សីដទៃផ្សេង ទៀត ដោយរួមទាំងនាយកដ្ឋាន DCS ផ្ដល់ឲ្យនៅពេលធ្វើសវនាការ ។ បើសិនជាអ្នកមានក្រដាសពត៌មានដែលអ្នកចង់ឲ្យចៅក្រម ALJ អាន, សូមឲ្យប្រាកដផ្ញើឬយកវាទៅឲ្យនាយកដ្ឋាន DCS មុនពេលធ្វើសវនាការរបស់អ្នក ។

នាយកដ្ឋាន DCS ត្រូវតែបានទទួលក្រដាសពត៌មានរបស់អ្នកយ៉ាងហោចណាស់ប្រាំ (5) ថ្ងៃធ្វើការមុនពេលធ្វើសវនាការ ។ បើសិនជាអាចធ្វើទៅបាន សូមផ្ញើក្រដាសពត៌មាន ឲ្យបានឆាប់បន្តិច ដើម្បីឲ្យក្រដាសចម្លងពត៌មាននោះអាចទៅដល់គូភាគីដទៃទៀត ។ នាយកដ្ឋាន DCS ថតគ្រប់ក្រដាសពត៌មានទាំងអស់ដែលអ្នកផ្ញើរួចហើយកំទេចចោល ។ ផ្ញើតែក្រដាសចម្លងឯកសារ និងកុំផ្ញើសំណៅដើមឲ្យសោះ ។

សូមផ្ញើក្រដាសចម្លងនៃពត៌មានទៅឲ្យគូភាគីដទៃទៀតផងដែរ បើសិនជាអ្នកមានអាសយដ្ឋានរបស់គេ ។ សូមជំរាបទៅនាយកដ្ឋាន DCS បើសិនជាអ្នកមិនអាចផ្ញើឯកសារទាំងនោះទៅឲ្យគូភាគីដទៃទៀតបាន ។

អ្នកអាចនាំសាក្សីឬក្រដាសថ្លែងការដែលមានចុះហត្ថលេខា, បានស្បថ, និងមានចុះថ្ងៃខែទៅកន្លែងសវនាការ ។ គ្រប់គូភាគីដទៃទៀតមានសិទ្ធិអានភស្តុតាងរបស់អ្នក និងស្គាល់សាក្សីរបស់អ្នកជានរណា មុនពេលធ្វើសវនាការ ។

នៅពេលអញ្ជើញមកធ្វើសវនាការ ចូរយកកញ្ចប់នៃសេចក្ដីថ្លែង (ក្រដាសពត៌មាន, រួមទាំង កំណត់ហេតុនានា) ដែលនាយកដ្ឋាន DCS បានផ្ញើឲ្យអ្នក ។ យកឯកសារដទៃផ្សេងទៀត ដែលអ្នកមានអារម្មណ៍ថា នឹងគាំទ្រសំណុំរឿងរបស់អ្នក ។ នាយកដ្ឋាន DCS នឹងផ្ញើ សំណៅចម្លងនៃឯកសារណាមួយដែលអ្នកផ្ញើទៅឲ្យគ្រប់គូភាគីទាំងអស់នៅពេលធ្វើ សវនាការ ។ **គូសខ្មៅកុំឲ្យឃើញអាសយដ្ឋានរបស់អ្នកនិងពត៌មានដទៃទៀតដែលអ្នកមិនចង់ បញ្ចេញទៅឲ្យគូភាគីដទៃទៀត ។**

## តើពត៌មានប្រភេទណាដែលខ្ញុំគួរយកទៅពេលធ្វើសវនាការ ?

នៅពេលអ្នកអញ្ជើញទៅធ្វើសវនាការ ចូរយកក្រដាសពត៌មាននានា, ដោយរួមទាំងសេចក្តីជូនដំណឹងនៃនាយកដ្ឋាន DCS ដែលបានផ្ញើឲ្យអ្នក ។ យកឯកសារណាមួយដែល អ្នកគិតថានឹងគាំទ្រសំណុំរឿងរបស់អ្នក, ដែលអាចមានរួមទាំងពត៌មានដូចខាងក្រោមនេះ:

- សំណៅចម្លងក្រដាសរៀបចំប្រាក់ពន្ធសហពន្ធ សំរាប់ពីរឆ្នាំចុងក្រោយ
- ក្រដាសគណនាបង្ហាញពីប្រាក់ឧបត្ថម្ភក្មេងដែលបានបំពេញ តែពត៌មានរបស់អ្នកប៉ុណ្ណោះ
- ដីកាបញ្ជាការឧបត្ថម្ភក្មេងដទៃទៀត
- ក្រដាសពត៌មានដែលបង្ហាញអំពី:
  - ចំនួនប្រាក់ប៉ុន្មានដែលអ្នករកបាន (ដូចជាកន្ទុយសែក, របាយការណ៍ប្រាក់បំណាច់, ឬសែកប្រាក់ពិការភាព)
  - ថ្លៃពេទ្យ
  - តំលៃការធានារ៉ាប់រងផ្នែកពេទ្យដែលអ្នកបានបង់ ដើម្បីធានារ៉ាប់រងក្មេង ឬក្មេងទាំងអស់
  - បង្កាន់ដៃសំរាប់មើលថែក្មេង, មើលថែសុខភាព, និងចំណាយដទៃផ្សេងទៀតសំរាប់ក្មេង
- លិខិតបញ្ជាក់នៃការបង់ប្រាក់ឧបត្ថម្ភណាមួយ
- លិខិតបញ្ជាក់នៃឱកាសពិសេសណាមួយ ឬការបង់ប្រាក់នានាដែលអ្នកចង់ឲ្យចៅក្រមយកមកពិចារណា
- ភស្តុតាងដទៃណាមួយដែលអ្នកចង់ឲ្យចៅក្រមយកមកពិចារណា

កំណត់ចំណាំ: ប្រភេទនៃសវនាការផ្សេងគ្នា ត្រូវឲ្យមានឯកសារផ្សេងគ្នា

## តើសិទ្ធិរបស់ខ្ញុំមានអ្វីខ្លះនៅក្នុងការធ្វើសវនាការការឧបត្ថម្ភក្មេង?

- អ្នកគ្មានសិទ្ធិទទួលជំនួយផ្នែកច្បាប់ដោយមិនបង់ប្រាក់ទេ ។
- អ្នកអាចតំណាងឲ្យខ្លួនអ្នក ឬដោយអ្នកណាម្នាក់ ដូចជាមេធាវី, មិត្តសំឡាញ់ ឬសាច់ញាតិ។
- អ្នកអាចបង្ហាញភស្តុតាង នឹងជំទាស់ភស្តុតាងដែលបានបង្ហាញដោយអ្នកណាម្នាក់ផ្សេងទៀត ។
- អ្នកអាចស្នើសុំឲ្យចៅក្រម ALJ លើកពេលវេលា (ពន្យាពេល) នៃការធ្វើសវនាការ បើសិនជាអ្នកមូលហេតុល្អ ។
- អ្នកមើលនិងទទួលយកសំណៅចម្លងឯកសារដែលទាក់ទងនឹងសំណុំរឿងរបស់អ្នក នៅមុនពេល, នៅពេល, ឬក្រោយពេលធ្វើសវនាការ ។
- អ្នកអាចទទួលក្រដាសថតចម្លងឯកសាររបស់នាយកដ្ឋាន DCS ដែលសំខាន់សំរាប់សវនាការ ដោយមិនចាំបាច់បង់ថ្លៃ បើសិនជាអ្នកមិនអាចចេញប្រាក់បង់បាន ។
- អ្នកអាចស្នើសុំភស្តុតាងពីអ្នកតំណាងនាយកដ្ឋាន DCS ដែលនាយកដ្ឋាន DCS មានបំណងប្រើមុនពេលធ្វើសវនាការ ។
- អ្នកអាចស្នើសុំឲ្យចៅក្រម ALJ អនុញ្ញាតឲ្យអ្នកផ្ញើភស្តុតាងច្រើនទៀតក្រោយពេលធ្វើសវនាការ ។
- អ្នកអាចសួរសំនួរទៅសាក្សី, ជំទាស់ទៅសាក្សី, និងយកភស្តុតាងដើម្បីបង្ហាញសក្ខីភាពចំពោះសាក្សីណាដែលប្រាប់មិនពិត ។
- អ្នកអាចនាំសាក្សីមក និងស្នើសុំទៅចៅក្រម ALJ ឲ្យអនុញ្ញាតសាក្សីនោះចូលរួមចំណែក ពេលធ្វើសវនាការ ។ អ្នកក៏អាចស្នើសុំទៅចៅក្រម ALJ ឲ្យអនុញ្ញាតសាក្សីនោះផ្ញើឬយកក្រដាសពត៌មានដែលចាំបាច់ពេលធ្វើសវនាការ ។ នាយកដ្ឋាន DCS មានសិទ្ធិបង្ហាញសាក្សីរបស់នាយកដ្ឋាន DCS ហើយនិងសួរសំនួរទៅសាក្សីរបស់អ្នកបាន ។
- អ្នកអាចស្នើសុំទៅចៅក្រម ALJ ឲ្យបញ្ជាទៅសាក្សីឲ្យនៅរង់ចាំខាងក្រៅបន្ទប់ធ្វើសវនាការ ។ ករណីនេះអាចការពារសិទ្ធិឯកជន និងរក្សាសាក្សីម្នាក់កុំឲ្យទទួលឥទ្ធិពលពីសាក្សីដទៃទៀត ។
- អ្នកអាចមើលឬទទួលក្រដាសចម្លងនៃបទបញ្ញត្តិ, ច្បាប់, គោលការណ៍ណែនាំ, និងការ បោះពុម្ពផ្សាយដទៃទៀតរបស់នាយកដ្ឋាន DCS ដែលទាក់ទងសវនាការរបស់អ្នក ។
- អ្នកអាចស្នើសុំឲ្យប្តូរសវនាការតាមទូរស័ព្ទ ឲ្យទៅជាសវនាការ"ដោយផ្ទាល់ខ្លួន" បើសិនជា អ្នកមានមូលហេតុល្អ ។ ការធ្វើសវនាការ"ដោយផ្ទាល់ខ្លួន"មានន័យថា អ្នកនឹងត្រូវអញ្ជើញទៅ ក្នុងបន្ទប់ជាមួយនឹងចៅក្រម ALJ នៅពេលធ្វើសវនាការ ។

## តើចៅក្រម ALJ សំរេចយ៉ាងដូចម្តេច ?

បើសិនជាមូលហេតុនៃសវនាការរបស់អ្នកគឺជាការបង្កើតឬកំណែប្រែការឧបត្ថម្ភក្មេង ចៅក្រម ALJ ធ្វើការសំរេចដោយប្រើតារាង Washington State Child Support Schedule (តារាងបង់ប្រាក់នៃការឧបត្ថម្ភក្មេងនៃរដ្ឋវ៉ាស៊ិនតោន) នៅក្រោមច្បាប់ជំពូក 26.19 RCW ។

នៅពេលមានដីកាបញ្ជាតុលាការជាន់ខ្ពស់ ចៅក្រម ALJ ធ្វើតាមការណែនាំនៅក្នុងដីកាបញ្ជា ។

## តើមានអ្វីកើតឡើងក្រោយពេលធ្វើសវនាការរួចហើយ ?

ចៅក្រម ALJ មិនធ្វើការសំរេចចុងក្រោយបង្អស់នៅពេលធ្វើសវនាការទេ ។ ចៅក្រម ALJ ផ្ញើដីកាបញ្ជាទៅឲ្យអ្នកប្រហែលជាបីអាទិត្យក្រោយពេលធ្វើសវនាការ ។ គឺជាការទទួលខុសត្រូវរបស់អ្នកដើម្បីធ្វើការធានាថាការិយាល័យ OAH មានអាសយដ្ឋានបច្ចុប្បន្ន របស់អ្នក ។ ការិយាល័យ OAH ផ្ញើដីកាទៅតាមអាសយដ្ឋានចុងក្រោយរបស់អ្នកដែលគេបានដឹង ។ បើសិនជាអ្នកមិនទទួលក្រដាសចម្លងដីកាបញ្ជារបស់អ្នក ចូរទូរស័ព្ទទៅនាយកដ្ឋាន DCS តាមលេខ 800-442-KIDS ។

សវនាការរបស់អ្នកគឺត្រូវតែមានសុពលភាព ទោះជាអ្នកមិនបានទទួលក្រដាសចម្លងដីកាបញ្ជា នោះក៏ដោយ ។

## តើយ៉ាងណាបើសិនជាខ្ញុំមិនចូលចិត្តការសំរេចរបស់ចៅក្រម ALJ ?

ដីកាបញ្ជានឹងមានពត៌មានអំពីសិទ្ធិធ្វើឧទ្ធរណ៍របស់អ្នក ។ បើសិនជាចៅក្រម ALJ បានចេញដីកាបញ្ជាចុងបញ្ចប់ អ្នកអាចដាក់បណ្តឹងទាមទារទៅតុលាការជាន់ខ្ពស់ ដើម្បីឲ្យមានចៅក្រមពិនិត្យដីកាបញ្ជានោះឡើងវិញ ។

## តើខ្ញុំអាចរកច្បាប់សំរាប់ធ្វើសវនាការនៅទីណា ?

អ្នកគួរតែមើលច្បាប់ដែលអនុវត្តសំរាប់ធ្វើសវនាការឧបត្ថម្ភក្មេង ។ ក្រដាសចម្លងនៃច្បាប់រដ្ឋវ៉ាស៊ិនតោនគឺមាននៅបណ្ណាល័យច្បាប់និងបណ្ណាល័យសាធារណៈ ។ អ្នកក៏អាចមើលច្បាប់នេះតាមបណ្តាញអ៊ិនធើណែត**:**

- ច្បាប់កំណែប្រែនៃរដ្ឋវ៉ាស៊ិនតោន (RCW)
  http://mrsc.org/rcw.htm
- ច្បាប់អភិបាលកិច្ចនៃរដ្ឋវ៉ាស៊ិនតោន (WAC)
  http://mrsc.org/wac.htm
  (ទៅមើលច្បាប់ WAC ជំពូក 388-14A និង 388-02)។

## តើយ៉ាងណាបើសិនជាខ្ញុំមានសំនួរជាច្រើន ?

បើសិនជាអ្នកមានសំនួរនានាដែលគ្មានចម្លើយនៅក្នុងកូនសៀវភៅ អ្នកអាចៈ

1. ទូរស័ព្ទទៅនាយកដ្ឋានឧបត្ថម្ភក្មេង (DCS);
2. ទូរស័ព្ទទៅការិយាល័យសវនាការរដ្ឋបាល (OAH); ឬ
3. ទាក់ទងមេធាវីម្នាក់ ។

## តើយ៉ាងណាបើសិនជាខ្ញុំមិនចេះនិយាយភាសាអង់គ្លេសបានល្អ ?

បើសិនជាអ្នកឬសាក្សីនិមួយៗត្រូវការអ្នកបកប្រែឯកសារឬអ្នកបកប្រែផ្ទាល់មាត់ម្នាក់ ការិយាល័យ OAH នឹងផ្តល់អ្នកបកប្រែភាសាដែលមានវិញ្ញាបនប័ត្រដោយមិនគិតឈ្នួលម្នាក់ ។ អ្នកអាចស្នើសុំអ្នកបកប្រែម្នាក់ យ៉ាងហោចណាស់ឲ្យបានមួយអាទិត្យមុនពេលធ្វើសវនាការ ។ មិត្តសំឡាញ់ឬសាច់ញាតិមិនអាចជាអ្នកបកប្រែភាសារបស់អ្នកទេ ។

## តើយ៉ាងណាបើសិនជាខ្ញុំត្រូវការជួយសម្របសម្រួលពិសេស ?

គ្រប់ការិយាល័យ DSHS, DCS និង OAH អាចមានផ្លូវសំរាប់ឲ្យកៅអីរទេះចេញចូលបាន ។ យ៉ាងហោចណាស់ ស្នើសុំឲ្យបានមួយអាទិត្យមុនពេលធ្វើសវនាការ បើសិនជាអ្នក ឬសាក្សីត្រូវការជំនួយពិសេសដូចជា :

- អ្នកបកប្រែភាសាសញ្ញាដោយមានវិញ្ញាបនប័ត្រ ឬ
- សម្ភារៈជាអក្សរតួធំៗ ឬទម្រង់ដទៃទៀត

រដ្ឋវ៉ាស៊ិនតោនផ្តល់ជំនួយដោយមិនយកឈ្នួល បើសិនជាអ្នកឬសាក្សីត្រូវការអ្នកបកប្រែឯកសារឬអ្នកបកប្រែភាសាផ្ទាល់មាត់, ឬអ្នកត្រូវការជំនួយពីព្រោះតែមានពិការភាព ។

សូមបំពេញនឹងផ្ញើក្រដាសសំរាប់ស្នើសុំជំនួយដែលភ្ជាប់មកជាមួយនេះទៅការិយាល័យសវនាការរដ្ឋបាល ។ សំរាប់សំរួលស្ថានការរបស់អ្នក យើងបានបោះពុម្ពអាសយដ្ឋាននៅខាងខ្នងក្រដាសនេះ ។

# ការស្នើសុំអ្នកបកប្រែឯកសារ, អ្នកបកប្រែភាសាផ្ទាល់មាត់, ឬជំនួយពិសេស

រដ្ឋផ្តល់ជំនួយដោយមិនយកឈ្នួល បើសិនជាអ្នកឬសាក្សីត្រូវការអ្នកបកប្រែឯកសារ ឬអ្នកបកប្រែភាសាផ្ទាល់មាត់ ឬត្រូវការជំនួយពីព្រោះតែមានពិការភាព ។

☐ ខ្ញុំត្រូវការទទួលឯកសារជា (ភាសា) ____ និង/ឬត្រូវការជំនួយពីអ្នកបកប្រែភាសា ។

☐ ខ្ញុំត្រូវជំនួយពិសេស (និយាយប្រាប់យើង អ្នកត្រូវការជំនួយអ្វី) ____

ឈ្មោះ ____

លេខទូរស័ព្ទ ____ លេខសំណុំរឿងនៃទាយកដ្ឋាន ឌជស ____

Postage
Required
Post Office will
not deliver
without proper
postage.

OFFICE OF ADMINISTRATIVE HEARINGS
PO BOX 42488
OLYMPIA WA 98504-2488

Washington State
Department of Social
& Health Services

DCS Division of Child Support